**ស្ថានទូតអូស្ត្រាលី**
**ភ្នំពេញ**

ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦

## ដំណើរទស្សនកិច្ចដោយឯកអគ្គរាជទូតអូស្ត្រាលីទៅកាន់ខេត្តបាត់ដំបង

ក្នុងសប្តាហ៍នេះ លោកស្រី **អេនជេលឡា ខកខឺរ៉េន** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា នឹងធ្វើដំណើរទស្សនកិច្ចជាផ្លូវការលើកដំបូងទៅកាន់ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

ដំណើរទស្សនកិច្ចរបស់លោកស្រីឯកអគ្គរាជទូត គឺដើម្បីគូសបញ្ជាក់ជាថ្មីម្តងទៀតនូវការគាំទ្ររបស់ប្រទេសអូស្ត្រាលីដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងខេត្តនេះ។

លោកស្រីនឹងពិនិត្យមើលសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជានៅថ្ងៃពុធ ព្រមទាំងជួបជាមួយសហគមន៍នានាដែលទទួលបានផលប្រយោជន៍ពីកម្មវិធីបោសសម្អាតមីនទាំងនេះផងដែរ។

ប្រទេសអូស្ត្រាលីមានប្រវត្តិយូរអង្វែងក្នុងការជួយដល់សកម្មភាពបោសសម្អាតមីននៅក្នុងប្រទេសកម្ពុជា និងកំពុងផ្តល់ទឹកប្រាក់ចំនួន៩លានដុល្លារអូស្ត្រាលីសម្រាប់ឆ្នាំ ២០១៦ ដល់២០១៩ តាមរយៈកម្មវិធី Clearing for Results របស់ UNDP។

លោកស្រីឯកអគ្គរាជទូតក៏នឹងជួបជាមួយស្ត្រីនៅក្នុងខេត្តបាត់ដំបង ដែលកំពុងទទួលបានការគាំទ្រពីកម្មវិធីលុបបំបាត់អំពើហិង្សាលើស្ត្រីផងដែរ។

ចាប់តាំងពីឆ្នាំ ២០១២ រាជរដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ទឹកប្រាក់ប្រមាណ១១លានដុល្លារអូស្ត្រាលីសម្រាប់កម្មវិធីនេះ។

លោកស្រីឯកអគ្គរាជទូតក៏នឹងជួបជាមួយតំណាងជាន់ខ្ពស់នៃរដ្ឋបាលខេត្តបាត់ដំបង និងខេត្តប៉ៃលិនផងដែរ។

នៅថ្ងៃព្រហស្បតិ៍ វេលាម៉ោង១១ព្រឹក សូមបើកវិទ្យុ ៩២.៧អេហ្វអេម ដើម្បីស្តាប់ប្រសាសន៍បន្ថែមទៀតរបស់លោកស្រីឯកអគ្គរាជទូត **អេនជេលឡា ខកខឺរ៉េន** អំពីការងារសំខាន់ៗដែលប្រទេសអូស្រ្តាលីកំពុងបំពេញនៅក្នុងខេត្តនេះ។

*សាកសួរព័ត៌មាន:* *Lauren Tuohy, ស្ថានទូតអូស្រ្តាលីភ្នំពេញ*

*Australian.Embassy.Cambodia@dfat.gov.au, 023 213 470*